CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ១៩ ខែមិថុនាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចនឹងចែកខែលការពារមុខដោយឥតគិតថ្លៃដល់របារ ភោជនីយដ្ឋាននិងហាងថែសម្ផស្សនិងថែខ្លួននៅឡុងប៊ិច

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - ថ្ងៃនេះនិងចុងសប្តាហ៍នេះទីក្រុងឡុងប៊ិចនឹងចែកខែលការពារមុខដោយឥតគិតថ្លៃដល់បារ ភោជនីយដ្ឋាន និងអាជីវកម្មថែសម្ផស្សនិងថែខ្លួននៅឡុងប៊ិចក្នុងកិច្ចខិតខំផ្តល់នូវឧបករណ៍សុវត្ថិភាពដែលត្រូវការដល់អាជីវកម្មដែលអាចនឹងមិនមានលទ្ធភាពរកឧបករណ៍ទាំងនោះដើម្បីបើកជាថ្មីភ្លាមៗបាននៅចុងសប្តាហ៍នេះឬចុងសប្តាហ៍បន្ទាប់។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "នៅពេលដែលយើងចាប់ផ្តើមបើកដំណើរការសេដ្ឋកិច្ចរបស់យើងឡើងវិញបន្តិចម្តងៗយើងត្រូវតែយកចិត្តទុកដាក់ខ្ពស់ក្នុងការរក្សាសុវត្ថិភាពនិងសុខភាពរបស់គ្នាទៅវិញទៅមក។ ការផ្តល់ខែលការពារមុខដល់អាជីវកម្មខ្នាតតូចរបស់យើងនិងនិយោជិករបស់ពួកគេគឺជាមធ្យោបាយតូចមួយដែលយើងអាចធ្វើដើម្បីជួយដល់អាជីវកម្មក្នុងក្រុងបើកដំណើរការឡើងវិញដោយសុវត្ថិភាព។"

បទបញ្ជាសុខភាពដែលត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃនេះថ្ងៃទី ១៩ ខែមិថុនាតម្រូវឱ្យអតិថិជនបារនិងកន្លែងធ្វើស្រាទំពាំងបាយជូរពាក់របាំងមុខនៅពេលចូលទៅក្នុងទីតាំងឬដើរពីកន្លែងមួយទៅកន្លែងមួយនៅក្នុងហាងនិងតម្រូវអោយអ្នកលាយស្រានិង/ឬអ្នកបំរើត្រូវពាក់បាំងមុខនិងខែលការពារមុខសម្រាប់

ការការពារនៅពេលបម្រើដល់អតិថិជនដែលមិនបានពាក់របាំងមុខ។ អ្នករត់តុនៅក្នុងភោជនីយដ្ឋានដែលបើកសម្រាប់បរិភោគអាហារនៅខាងក្នុងតម្រូវឱ្យពាក់ទាំងរបាំងមុខធ្វើពីក្រណាត់និងខែលការពារមុខដើម្បីបង្កើនការការពារដល់និយោជិកនិងអតិថិជន។ លើសពីនេះទៀតនៅថ្ងៃទី ២៦ ខែមិថុនាហាងថែសម្ផស្សនិងថែខ្លួនជាច្រើននឹងត្រូវបានអនុញ្ញាតឱ្យបើកឡើងវិញ។ ក្នុងបទបញ្ជាសុខភាពមួយថ្មីដែលនឹងចេញនាពេលខាងមុខអ្នកផ្តល់សេវាត្រូវតែពាក់ខែលការពារមុខនៅពេលផ្តល់សេវាកម្មថែសម្ផស្សឬថែខ្លួនដែលតម្រូវឱ្យអតិថិជនដោះរបាំងមុខចេញដើម្បីផ្តល់សេវាកម្មបាន។

អ្នកតំណាងបារភោជនីយដ្ឋាននិងហាងថែសម្ផស្សនិងថែខ្លួនអាចមកយកខែលការពារមុខនៅចំណតរថយន្តការិយាល័យកណ្តាលរបស់មន្ទីរពន្លត់អគ្គីភ័យនៃឡុងប៊ិចដែលមានទីតាំងនៅ 3205 Lakewood Blvd។ ខែលការពារមុខមានកំណត់ត្រឹម ២០ ខែលក្នុងមួយហាងហើយអ្នកដែលមកដល់មុននឹងត្រូវបម្រើមុនរហូតទាល់តែខែលអស់។ អ្នកតំណាងអាជីវកម្មនីមួយៗនឹងត្រូវផ្តល់ឈ្មោះនិងឈ្មោះអាជីវកម្មរបស់ពួកគាត់ពេលដែលមកយកខែល។

ខែលនឹងមានសម្រាប់ការមកយករហូតដល់ចុងសប្តាហ៍នេះនៅថ្ងៃនិងម៉ោងដូចខាងក្រោម៖

- ថ្ងៃសុក្រទី 19 ខែមិថុនាចាប់ពីម៉ោង 1 រសៀលដល់ម៉ោង 4 រសៀល
- ថ្ងៃសៅរ៍ទី 20 ខែមិថុនាចាប់ពីម៉ោង 9 ព្រឹកដល់ម៉ោង 12 ថ្ងៃត្រង់
- ថ្ងៃអាទិត្យទី 21 ខែមិថុនាចាប់ពីម៉ោង 9 ព្រឹកដល់ម៉ោង 12 ថ្ងៃត្រង់

ទីក្រុងឡុងប៊ិចបានចែកខែលការពារមុខដោយឥតគិតថ្លៃដល់ភោជនីយដ្ឋានមួយចំនួនដែលមានមូលដ្ឋាននៅឡុងប៊ិចកាលពីខែឧសភា។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើប្រពន្ធ័សង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

\# # #